ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៦៩/១៥ គជបជ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមការងារកិច្ចការយុត្តិធម៌

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ:០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការ បង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចរាជរដ្ឋាភិបាល លេខ ១៤៥ សសរ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- បានឃើញសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# សម្រេច

**ប្រការ១.**

ត្រូវបានតែងតាំងសមាសភាព នៃក្រុមការងារកិច្ចការយុត្តិធម៌ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដែលមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តម **អង្គ វង្ស វឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ **ប្រធាន**

| | | | |
|---|---|---|---|
| ២. ឯកឧត្តម | **ភើត រិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោក | **ទ៉ែត សារ៉ាត** | ព្រះរាជអាជ្ញា នៃមហាអយ្យការ អមសាលាឧទ្ធរណ៍ | អនុប្រធាន |
| ៤. ឯកឧត្តម | **ប៉ែន ពេជ្រសាលី** | អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអេយ្យការ | អនុប្រធាន |
| ៥. ឯកឧត្តម ឧ.ទោ | **ឃឹម ទិរៈ** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| ៦. ឯកឧត្តម | **តូច ចាន់នី** | អគ្គនាយកបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧. ឯកឧត្តម | **សូ ឌីម៉ា** | អនុប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៨. ឯកឧត្តម ឧ.ឯក | **ឃុន សំបូរ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ៩. លោកជំទាវ ឧ.ឯក | **ឌុច ដាណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ១០. លោក | **គឹម សុវណ្ណា** | អនុប្រធាននាយកដ្ឋានច្បាប់ កុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១. លោក | **សុច សុផាន់ណារ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការអេយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ | សមាជិក |
| ១២. លោកស្រី | **ស៊ុន វណ្ណា** | អគ្គនាយករងក្រសួងកិច្ចការនារី | សមាជិក |
| ១៣. លោក ឧ.ទោ | **ជីវ ផល្លី** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៤. លោក ឧ.ត្រី | **លី ឡាយ** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៥. លោកវ.ឯក | **សូរ សារិន** | ស្នងការរង ស្នងការដ្ឋានយុត្តិធម៌ នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៦. លោក | **ឌី មថិលា** | អនុប្រធានការិយាល័យ ក្រសួងយុត្តិធម៌ | សមាជិក |
| ១៧. | តំណាង | អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិ | សមាជិក។ |

**ប្រការ២.**

ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារកិច្ចការយុត្តិធម៌ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ច ដូចមានចែងក្នុងប្រការ៦ នៃសេចក្តីសម្រេចគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពី ការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព ។ ប្រធានក្រុមការងារ អាចចាត់តាំងមន្ត្រីជាជំនួយតាមការចាំបាច់ ។

អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិដែលមានគោលដៅស្របទៅនឹងភារកិច្ចដែលកំណត់ដោយសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ខាងលើនេះ អាចស្នើសុំចូលជាសមាជិកក្រុមការងារ មកប្រធានក្រុមការងារកិច្ចការយុត្តិធម៌ និងចាត់តំណាងផ្លូវការមកចូលរួម តាមការអញ្ជើញរបស់ប្រធានក្រុម ។

**ប្រការ៣.**

ក្រសួងយុត្តិធម៌ ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិ និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យក្រសួងយុត្តិធម៌
- អគ្គលេខាធិការ គ.ជ.ប.ជ
- ក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ
- ក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ
- សាមីខ្លួនដូចប្រការ១
- នាយកដ្ឋាននីតិកម្ម ក្រសួងមហាផ្ទៃ
- ឯកសារ កាលប្បវត្តិ